# ព័ត៌មានអំពីការចាក់បញ្ចូលឈាម៖

ខិតប័ណ្ណព័ត៌មាននេះ ពន្យល់ពីហេតុអ្វីបានជាអ្នកអាចត្រូវការចាក់បញ្ចូលឈាម និងអ្វីខ្លះដែលត្រូវរំពឹងទុក។ សូមពិគ្រោះជាមួយវេជ្ជបណ្ឌិតរបស់អ្នកអំពីមូលហេតុដែលអ្នកត្រូវការ (ឬអាចត្រូវការ) ការចាក់បញ្ចូលឈាម ហើយថាតើមានជម្រើសផ្សេងទៀត នៅក្នុងករណីរបស់អ្នកដែរឬអត់។

## ហេតុអ្វីបានជាខ្ញុំអាចត្រូវការចាក់បញ្ចូលឈាម?

អ្នកអាចត្រូវការចាក់បញ្ចូលឈាម ប្រសិនបើ៖

> អ្នកបាត់បង់ឈាមយ៉ាងច្រើនក្នុងការវះកាត់ ការសម្រាលកូន ឬបន្ទាប់ពីគ្រោះថ្នាក់មួយដ៏ធ្ងន់ធ្ងរ។

> មានជំងឺស្លេកស្លាំង (កង្វះកោសិកាឈាមក្រហម) ដែលមិនអាចព្យាបាលដោយថ្នាំជាតិដែក ឬវីតាមីនផ្សេងទៀតតែមួយមុខនោះ។

> រាងកាយរបស់អ្នកមិនអាចធ្វើឱ្យកោសិកាឈាមថ្មីមានសុខភាពល្អគ្រប់គ្រាន់។ ការនេះប្រហែលជាដោយសារមានបញ្ហាខួរឆ្អឹង ឬផលប៉ះពាល់បន្ទាប់បន្សំនៃការព្យាបាលដោយសារធាតុគីមី។

## តើការចាក់បញ្ចូលឈាមមានប៉ុន្មានប្រភេទ?

ការបរិច្ចាគឈាមត្រូវបានបែងចែកជាផ្នែកផ្សេងៗគ្នា ហើយត្រូវបានរក្សាទុកនៅក្នុងថង់ ឬដបពិសេស។ បន្ទាប់មកអ្នកអាចត្រូវបានផ្តល់ឱ្យតែមួយចំណែកប៉ុណ្ណោះដែលរាងកាយរបស់អ្នកត្រូវការ ។ ផ្នែកសំខាន់ទាំង៣ រួមមាន៖

> កោសិកាឈាមក្រហម ដែលនាំយកអុកស៊ីសែនទៅឲ្យជាលិកា និងសរីរាង្គទាំងឡាយ។

> គ្រាប់ឈាមដែលធ្វើឲ្យឈាមកក ដែលជួយបញ្ឈប់ការហូរឈាម។

> ប្លាស្មាដែលមានសារធាតុបង្កកឈាម (ដើម្បីជួយបញ្ឈប់ការហូរឈាម) និងប្រូតេអ៊ីន និងអង្គបដិបក្ខក្នុងខ្លួនផ្សេងទៀត ។

## តើការចាក់បញ្ចូលឈាមមានហានិភ័យអ្វីខ្លះ?

ប្រទេសអូស្ត្រាលីមានការផ្គត់ផ្គង់ឈាមដែលមានសុវត្ថិភាពបំផុតនៅលើពិភពលោក ក៏ប៉ុន្តែដូចគ្នានឹងវិធីព្យាបាលទាំងអស់ដែរ ការចាក់បញ្ចូលឈាមនៅតែមានការប្រឈមនឹងគ្រោះហានិភ័យ។

ហានិភ័យទូទៅបំផុតនៃការចាក់បញ្ចូលឈាម រួមមាន៖

> ប្រតិកម្មតិចតួចដូចជាក្តៅខ្លួនកម្រិតស្រាល និងកន្ទួលលើស្បែក។

> ការមានផ្ទុកសារធាតុរាវលើស ដែលបណ្តាលឱ្យពិបាកដកដង្ហើម ជាពិសេសចំពោះមនុស្សវ័យចំណាស់ និងអ្នកដែលមានបញ្ហាបេះដូង។

ហានិភ័យនៃការបញ្ចូលឈាមដែលមានកម្រិតទាប រួមមាន៖

> ទទួលបានឈាមដែលមិន "ត្រូវសម" ជាមួយអ្នក។

> ប្រតិកម្មធ្ងន់ធ្ងរ ឧទាហរណ៍ ដូចការទាស់ ឬរបួសសួតស្រួចស្រាវ។

> ការចម្លងមេរោគ ឧទាហរណ៍ ដូចជាបាក់តេរី ឬវីរុស។

បុគ្គលិកបានទទួលការបណ្តុះបណ្តាលលើការពិនិត្យយ៉ាងជិតដល់ចំពោះប្រតិកម្ម ហើយឆ្លើយតបយ៉ាងឆាប់រហ័ស។

## តើគេចាក់បញ្ចូលឈាមតាមវិធីណា?

ឈាមត្រូវបានចាក់បញ្ចូលទៅក្នុងសរសៃឈាមវ៉ែន ជាធម្មតាតាមកំភួនដៃ ឬដៃរបស់អ្នកដោយប្រើបំពង់ប្លាស្ទិចទន់។

កញ្ចប់ថង់ឈាម(ឯកតា) នីមួយៗ អាចចំណាយរហូតដល់ទៅ៤ម៉ោង ក៏ប៉ុន្តែអាចចាក់បញ្ចូលលឿនជាងនេះក្នុងករណីចាំបាច់។

បុគ្គលិកគ្លីនិកនឹងធ្វើការត្រួតពិនិត្យយ៉ាងហ្មត់ចត់លើអត្តសញ្ញាណរបស់អ្នក នៅពេលដែលគំរូឈាមត្រូវបានបូម ហើយធ្វើម្តងទៀត មុនពេលចាក់បញ្ចូលឈាមឲ្យអ្នក។ វាជាការសំខាន់ដែលអ្នកពាក់បង់សម្គាល់ខ្លួន និងបញ្ជាក់ឈ្មោះ និងថ្ងៃខែឆ្នាំកំណើតរបស់អ្នក នៅពេលគេសួរ។ គេធ្វើដូច្នេះគឺដើម្បីការពារអ្នកមិនឲ្យគេផ្តល់ឈាមខុស (សម្រាប់អ្នកផ្សេងទៀត)។ សូមនិយាយចេញ ប្រសិនបើមានបញ្ហាណាមួយនៅពេលបុគ្គលិកពិនិត្យអត្តសញ្ញាណរបស់អ្នក។ ត្រូវធ្វើឱ្យប្រាកដថាព័ត៌មានលម្អិតរបស់អ្នក(រួមទាំងអក្ខរាវិរុទ្ធ) គឺត្រឹមត្រូវ១០០ភាគរយ។

Government of South Australia

SA Health

© Department for Health & Ageing, Government of South Australia.
រក្សាសិទ្ធិគ្រប់យ៉ាង។ *BloodSafe TP-L3-813 v1.0 2016*

## តើខ្ញុំនឹងមានអារម្មណ៍ដូចម្តេចក្នុងអំឡុងពេលចាក់បញ្ចូលឈាម?

មនុស្សភាគច្រើនពុំនអារម្មណ៍ខុសប្លែកអ្វីទេក្នុងអំឡុងពេលចាក់បញ្ចូលឈាម។ អ្នកខ្លះ មានអារម្មណ៍ក្តៅខ្លួនបន្តិច គ្រុនរងា ឬកន្ទួល។ អាការៈទាំងនេះគឺធម្មតា ដោយសារមានប្រតិកម្មស្រាល ឬប្រតិកម្មទាស់។ អាការៈទាំងនេះអាចបានព្យាបាល ដោយថ្នាំ (ដើម្បីកាត់បន្ថយគ្រុនក្តៅ) ឬដោយចាក់បញ្ចូលឈាមឱ្យកាន់តែយឺត។

បុគ្គលិកនឹងតាមដានអ្នកដោយប្រុងប្រយ័ត្ន ចំពោះបញ្ហាណាមួយក្នុងអំឡុងពេលចាក់បញ្ចូលឈាម។ ការនេះមានន័យថា ត្រូវពិនិត្យជីពចរ សម្ពាធឈាម និងសីតុណ្ហភាពរបស់អ្នកឲ្យបានទៀងទាត់។ ប្រសិនបើអ្នកមានអារម្មណ៍មិនស្រួលខ្លួនក្នុង អំឡុងពេលចាក់បញ្ចូលឈាម វាជាការសំខាន់ដែលអ្នកត្រូវជម្រាបប្រាប់គិលានុបដ្ឋាកឲ្យបានដឹងភ្លាម។

## តើខ្ញុំអាចបដិសេធការចាក់បញ្ចូលឈាមបានឬទេ?

ការព្យាបាល គឺជាជម្រើសរបស់អ្នកទេ។ អ្នកមានសិទ្ធិក្នុងការបដិសេធ ក៏ប៉ុន្តែត្រូវយល់ឱ្យច្បាស់ពីផលវិបាកនៃការបដិសេធ នេះ មុនពេលធ្វើដូច្នេះ។ ប្រសិនបើអ្នកមានហេតុផលណាមួយ ដែលបដិសេធមិនទទួលយកការចាក់បញ្ចូលឈាម សូម ជម្រាបប្រាប់វេជ្ជបណ្ឌិតឲ្យដឹងឥឡូវនេះ។

## កិច្ចការខ្លះៗដែលត្រូវសួរវេជ្ជបណ្ឌិតរបស់អ្នក

- ☐ ហេតុអ្វីបានជាខ្ញុំត្រូវការចាក់បញ្ចូលឈាម?
- ☐ ក្នុងករណីរបស់ខ្ញុំ តើមានអត្ថប្រយោជន៍ និងហានិភ័យអ្វីខ្លះ?
- ☐ តើមានជម្រើសផ្សេងទៀតឬទេ?
- ☐ មានអ្វីដែលអ្នកមិនយល់ មានការព្រួយបារម្ភ ឬចង់ឱ្យគេពន្យល់បន្ថែម។

ប្រសិនបើអ្នកកំពុងមានគម្រោងវះកាត់៖

- ☐ តើមានអ្វីដែលខ្ញុំអាចធ្វើបាន ដើម្បីកាត់បន្ថយតម្រូវការចាក់បញ្ចូលឈាមដែរឬទេ?
- ☐ តើខ្ញុំនឹងចាប់ផ្តើមស្លេកស្លាំង ឬមានជាតិដែកកម្រិតទាបឬទេ ហើយអាការៈបែបនេះអាចកែតម្រូវបានតាមវិធីណា?
- ☐ តើគេអាចប្រមូល និងផ្តល់ឈាមរបស់ខ្ញុំមកឱ្យខ្ញុំវិញ ដែលបានបាត់បង់ក្នុងអំឡុងពេលវះកាត់បានដែរឬទេ?

## កិច្ចការខ្លះៗដែលត្រូវប្រាប់វេជ្ជបណ្ឌិតរបស់អ្នក

អ្នកត្រូវប្រាប់វេជ្ជបណ្ឌិតរបស់អ្នក ប្រសិនបើអ្នក៖

- ☐ មានមូលហេតុណាមួយដែលបដិសេធមិនទទួលយកការចាក់បញ្ចូលឈាម។
- ☐ ធ្លាប់មានប្រតិកម្ម ឬបញ្ហាជាមួយការចាក់បញ្ចូលឈាមកាលពីកន្លងមក។
- ☐ ដឹងថាអ្នកមានតម្រូវការ ឬសេចក្តីត្រូវការពិសេសណាមួយសម្រាប់ការចាក់បញ្ចូលឈាម។
- ☐ កំពុងប្រើថ្នាំពង្រាវឈាមណាមួយ (ដូចជាថ្នាំអាស្ពីរីន, ថ្នាំ warfarin, ថ្នាំ clopidogrel, ថ្នាំ apixaban, ថ្នាំ dabigatran, ថ្នាំ rivaroxaban) ដែលអាចបង្កើនការហូរឈាម។ ប្រសិនបើអ្នកមានការវះកាត់ សូមសួរវេជ្ជបណ្ឌិតថាតើអ្នកគួរឈប់ លេបថ្នាំទាំងនេះមុនពេល និងនៅពេលវះកាត់ដែរឬអត់។ សូមចងចាំថាដើម្បីសុវត្ថិភាពអ្នក មានតែវេជ្ជបណ្ឌិតរបស់អ្នក ប៉ុណ្ណោះដែលអាចធ្វើការសម្រេចចិត្តលើបញ្ហានេះបាន ដោយសារតែគ្រោះហានិភ័យនៃការបញ្ឈប់នេះ អាចមានច្រើន ជាងអត្ថប្រយោជន៍។
- ☐ កំពុងប្រើថ្នាំណាមួយផ្សេងទៀត (រួមទាំងថ្នាំឫសឈើ) និងថ្នាំដែលគ្មានសំបុត្រពេទ្យ (គ្មានវេជ្ជបញ្ជា) ពីព្រោះថ្នាំមួយ ចំនួនទាំងនេះក៏អាចពង្រាវឈាមបានដែរ។

## ចុះប្រសិនបើខ្ញុំមានការបារម្ភផ្សេងទៀតអំពីការចាក់បញ្ចូលឈាម?

ប្រសិនបើអ្នកមានការព្រួយបារម្ភណាមួយ ទោះជាបញ្ហាបារម្ភនោះតូចក្តី អ្នកគួរពិគ្រោះជាមួយវេជ្ជបណ្ឌិតរបស់អ្នក គិលានុបដ្ឋាក ឬឆ្មប។

---

### សម្រាប់ព័ត៌មានបន្ថែម៖

ប្រសិនបើអ្នកមានលទ្ធភាពប្រើប្រាស់អ៊ីនធើណិត ហើយចង់ស្វែងយល់បន្ថែមអំពីការចាក់បញ្ចូលឈាម អ្នកអាចស្វែងរកព័ត៌មានដ៏មានប្រយោជន៍នៅលើវិបសាយ៖
www.mytransfusion.com.au

© Department for Health & Ageing, Government of South Australia.
រក្សាសិទ្ធិគ្រប់យ៉ាង។ *BloodSafe TP-L3-813 v1.0 2016*

* ក្រុមប្រឹក្សាសហគមន៍លើសុវត្ថិភាព និងគុណភាពសុខភាព SA (SQCAG)។
ឯកសារនេះត្រូវបានពិនិត្យឡើងវិញ និងអនុម័តដោយ SQCAG* សម្រាប់អ្នកប្រើប្រាស់ និងសហគមន៍ នៅខែសីហា ឆ្នាំ២០១៦

This document has been reviewed and endorsed by SQCAG* for consumers and the community August 2016.

Government of South Australia
SA Health

BloodSafe
សម្ព:សម្រាប់អ្នកជំងឺនៅ៖
www.sahealth.sa.gov.au/bloodorgantissue